នស/រកត/០១២៥/០៤៤

# ព្រះរាជក្រឹត្យ

## ស្ដីពី

## ការបង្កើតគណៈកម្មាធិការជាតិប៉ារ៉ាឡាំពិកកម្ពុជា

## យើង

## ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្តម សីហមុនី

## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ដ្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា ខេមរាស្រីពិរាស្ដ្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្ដីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្ដីពីការកែសម្រួលនិងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្ដីពីការកែសម្រួលនិងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧០៩/០១០ ចុះថ្ងៃទី៣ ខែកក្កដា ឆ្នាំ២០០៩ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីកិច្ចការពារនិងលើកកម្ពស់សិទ្ធិជនពិការ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៩១២/០០៧ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១២ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការអនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជាចូលជាភាគីនៃអនុសញ្ញាអង្គការសហប្រជាជាតិស្ដីពីសិទ្ធិជនពិការ

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

- បានទទួលយល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

# ត្រាស់បង្គាប់

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

ត្រូវបានបង្កើតគណៈកម្មាធិការជាតិប៉ារ៉ាឡាំពិកកម្ពុជា ដែលសរសេរជាអក្សរកាត់ថា **គ.ជ.ប.ក.** និងជាភាសាអង់គ្លេស NATIONAL PARALYMPIC COMMITTEE OF CAMBODIA សរសេរជាអក្សរកាត់ថា NPCC ជាយន្តការដឹកនាំ សម្របសម្រួល និងអនុវត្តសកម្មភាពកីឡារបស់ជនពិការទាំងថ្នាក់ជាតិនិងអន្តរជាតិ។

## ជំពូកទី២
## ភារកិច្ចរបស់ គ.ជ.ប.ក.

**មាត្រា២ .-**

**គ.ជ.ប.ក.** មានភារកិច្ចដូចតទៅៈ

- ដឹកនាំ គ្រប់គ្រង លើវិស័យកីឡារបស់ជនពិការកម្ពុជា និងធ្វើជាតំណាងលើវិស័យកីឡាជនពិការកម្ពុជាទាំងថ្នាក់ជាតិនិងអន្តរជាតិ
- ទទួលរៀបចំធ្វើជាម្ចាស់ផ្ទះថ្នាក់ជាតិនិងអន្តរជាតិនៃព្រឹត្តិការណ៍ប្រកួតកីឡាជនពិការ
- គាំទ្រ ពង្រឹងនិងពង្រីកសហព័ន្ធឬក្លឹបកីឡាជនពិការ ក្នុងនាមជាអាណាព្យាបាល
- គាំទ្រ សម្របសម្រួល និងធ្វើជាមគ្គុទ្ទេសក៍ក្នុងការដឹកនាំកីឡាជនពិការ ចូលរួមព្រឹត្តិការណ៍និងការប្រកួតកីឡាផ្សេងៗរបស់ជនពិការនៅក្នុងប្រទេសនិងក្រៅប្រទេស កម្រិតដើងឯក កម្រិតជាតិ កម្រិតតំបន់ កម្រិតអន្តរជាតិ និងកម្រិតពិភពលោក
- ចូលរួមផ្តល់អនុសាសន៍លើលិខិតបទដ្ឋានគតិយុត្តនិងបែបបទអនុវត្តបទដ្ឋានកីឡាអន្តរជាតិដែលពាក់ព័ន្ធ
- ធ្វើកិច្ចសហប្រតិបត្តិការជាមួយគ្រប់ក្រសួង ស្ថាប័ន អង្គភាពរដ្ឋ អាជ្ញាធរ អង្គការកីឡាជាតិនិងអន្តរជាតិ និងវិស័យឯកជន
- គាំទ្រ ផ្សព្វផ្សាយ និងអប់រំពីគុណតម្លៃកីឡា អត្ថប្រយោជន៍កីឡា និងទស្សនាទានឥទ្ធិពលកីឡាប៉ារ៉ាឡាំពិក។

## ជំពូកទី៣
## សមាសភាពរបស់ គ.ជ.ប.ក.

**មាត្រា៣ .-**

**គ.ជ.ប.ក.** មានសមាសភាពដូចតទៅៈ

| | |
|---|---|
| - នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា | ប្រធានកិត្តិយស |
| - សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** | ប្រធាន |
| - រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី | អនុប្រធានអចិន្ត្រៃយ៍ |

| | |
|---|---|
| - រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ | អនុប្រធាន |
| - រដ្ឋមន្ត្រីក្រសួងការពារជាតិ | អនុប្រធាន |
| - រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | អនុប្រធាន |
| - រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា | អនុប្រធាន |
| - រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | អនុប្រធាន |
| - ប្រធានសហភាពសហព័ន្ធយុវជនកម្ពុជា | អនុប្រធាន |
| - រដ្ឋមន្ត្រីក្រសួងព័ត៌មាន | សមាជិក |
| - រដ្ឋមន្ត្រីក្រសួងសុខាភិបាល | សមាជិក |
| - រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ | សមាជិក |
| - រដ្ឋមន្ត្រីក្រសួងទេសចរណ៍ | សមាជិក |
| - ប្រធានគណៈកម្មាធិការជាតិអូឡាំពិកកម្ពុជា | សមាជិក |
| - អគ្គស្នងការនគរបាលជាតិ | សមាជិក |
| - អគ្គមេបញ្ជាការកងយោធពលខេមរភូមិន្ទ | សមាជិក |
| - មេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស | សមាជិក |
| - អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត | សមាជិក |
| - អគ្គនាយកនៃអគ្គនាយកដ្ឋានកីឡានៃក្រសួងអប់រំ យុវជន និងកីឡា | សមាជិក |
| - ប្រធានមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រាជធានី ខេត្ត | សមាជិក |
| - អគ្គលេខាធិការនៃគណៈកម្មាធិការជាតិប៉ារ៉ាឡាំពិកកម្ពុជា | សមាជិកអចិន្ត្រៃយ៍។ |

**គ.ជ.ប.ក.** អាចមានសមាសភាពបន្ថែមផ្សេងទៀតដែលជាប្រធាន ឬតំណាងក្រសួង ស្ថាប័នពាក់ព័ន្ធរបស់រាជរដ្ឋាភិបាលតាមការចាំបាច់។ សមាសភាពបន្ថែមត្រូវកំណត់ដោយសេចក្ដីសម្រេចរបស់រាជរដ្ឋាភិបាល។

ប្រធានកិត្តិយសនិងប្រធាន **គ.ជ.ប.ក.** ត្រូវតែងតាំងដោយព្រះរាជក្រឹត្យ។

សមាសភាពជាក់ស្ដែងជាអនុប្រធាននិងសមាជិក ត្រូវតែងតាំងដោយសេចក្ដីសម្រេចរបស់រាជរដ្ឋាភិបាល។

## ជំពូកទី៤
## ការប្រព្រឹត្តទៅរបស់ គ.ជ.ប.ក.

**មាត្រា៤ .-**

**គ.ជ.ប.ក.** ត្រូវប្រជុំសាមញ្ញរៀងរាល់មួយឆ្នាំម្ដង។ ក្នុងករណីមានការចាំបាច់ **គ.ជ.ប.ក.** អាចប្រជុំវិសាមញ្ញតាមការកោះអញ្ជើញរបស់ប្រធាន **គ.ជ.ប.ក.**។ ប្រធាន **គ.ជ.ប.ក.** ត្រូវដឹកនាំអង្គប្រជុំ។ ក្នុងករណីប្រធានអវត្តមានឬមានធុរៈ ប្រធាន **គ.ជ.ប.ក.** អាចប្រគល់សិទ្ធិជូនអនុប្រធានអចិន្ត្រៃយ៍ឬអនុប្រធានណាម្នាក់ដើម្បីដឹកនាំកិច្ចប្រជុំជំនួស។

ក្នុងកិច្ចប្រជុំសាមញ្ញមួយឆ្នាំម្ដង **គ.ជ.ប.ក.** ត្រូវធ្វើរបាយការណ៍លទ្ធផលការងារអំពីសមិទ្ធផលនៃការអនុវត្តកម្មវិធីការងារដែលសម្រេចបាននិងផែនការដែលបានអនុម័តឱ្យអនុវត្តជូនអង្គប្រជុំប្រចាំឆ្នាំរបស់ **គ.ជ.ប.ក.** ក្រោមអធិបតីភាពប្រធានកិត្តិយស និងអធិបតីភាពប្រធាន **គ.ជ.ប.ក.** ឬតំណាង។

របៀបរបបការងារនិងកិច្ចដំណើរការប្រជុំរបស់ **គ.ជ.ប.ក.** ត្រូវកំណត់ដោយបទបញ្ជាផ្ទៃក្នុងរបស់ **គ.ជ.ប.ក.**។

**មាត្រា៥ .-**

**គ.ជ.ប.ក.** មានសិទ្ធិអញ្ជើញអ្នកជំនាញតំណាងក្រសួង ស្ថាប័នពាក់ព័ន្ធនានា និងអង្គការដៃគូអភិវឌ្ឍជាតិនិងអន្តរជាតិ ដែលពុំមានចែងក្នុងសមាសភាព **គ.ជ.ប.ក.** ក្នុងមាត្រា៣នៃព្រះរាជក្រឹត្យនេះ ដើម្បីចូលរួមប្រជុំផ្តល់យោបល់បច្ចេកទេសនិងផ្តល់អនុសាសន៍។

**មាត្រា៦ .-**

**គ.ជ.ប.ក.** អាចបង្កើតគណៈកម្មការជំនាញឬអនុគណៈកម្មការជំនាញ តាមការចាំបាច់ដោយសេចក្តីសម្រេចរបស់ប្រធាន **គ.ជ.ប.ក.**។

**គ.ជ.ប.ក.** អាចបង្កើតក្រុមការងារបច្ចេកទេសដើម្បីជួយការងារ **គ.ជ.ប.ក.**។ សមាសភាពក្រុមការងារបច្ចេកទេសត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ប្រធាន **គ.ជ.ប.ក.**។

**មាត្រា៧ .-**

**គ.ជ.ប.ក.** មានអគ្គលេខាធិការដ្ឋានមួយជាសេនាធិការសម្រាប់ដំណើរការការងារប្រចាំថ្ងៃ ដែលមានទីតាំងនៅទីស្តីការគណៈរដ្ឋមន្ត្រី។

អគ្គលេខាធិការដ្ឋាន **គ.ជ.ប.ក.** ត្រូវដឹកនាំដោយអគ្គលេខាធិការមួយរូប និងមានអគ្គលេខាធិការរងនិងសមាជិកមួយចំនួនតាមការចាំបាច់ ដោយអនុលោមតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន។

អគ្គលេខាធិការនិងអគ្គលេខាធិការរងត្រូវតែងតាំងដោយព្រះរាជក្រឹត្យ។

សមាជិកអគ្គលេខាធិការដ្ឋានត្រូវតែងតាំងដោយអនុក្រឹត្យ។

ក្នុងករណីចាំបាច់ អគ្គលេខាធិការដ្ឋាន **គ.ជ.ប.ក.** អាចស្នើសុំជ្រើសរើសមន្ត្រីជាប់កិច្ចសន្យាឱ្យជួយការងារ។

ការរៀបចំនិងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាន **គ.ជ.ប.ក.** ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ប្រធាន **គ.ជ.ប.ក.**។

**មាត្រា៨ .-**

**គ.ជ.ប.ក.** អាចមានទីប្រឹក្សាបច្ចេកទេសជាតិនិងអន្តរជាតិមួយចំនួន ដែលមានសមាសភាពជាអ្នកជំនាញដើម្បីជួយការងារ **គ.ជ.ប.ក.** និងអគ្គលេខាធិការដ្ឋាន **គ.ជ.ប.ក.**។

ទីប្រឹក្សាត្រូវតែងតាំងដោយអនុក្រឹត្យ។

**មាត្រា៩ .-**

**គ.ជ.ប.ក.** មានរូបសញ្ញានិងត្រាដោយឡែក សម្រាប់ដំណើរការការងារប្រចាំថ្ងៃរបស់ខ្លួន។

គំរូរូបសញ្ញារបស់ **គ.ជ.ប.ក.** មានកំណត់ក្នុងឧបសម្ព័ន្ធនៃព្រះរាជក្រឹត្យនេះ។

គំរូត្រាត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ **គ.ជ.ប.ក.**។

## ជំពូកទី៥

## ប្រភពធនធាន

**មាត្រា១០ .-**

**គ.ជ.ប.ក.** មានប្រភពធនធានផ្គត់ផ្គង់ដោយថវិកាជាតិជាកញ្ចប់ថវិកាដោយឡែកនៅក្នុងក្របខ័ណ្ឌថវិកាប្រចាំឆ្នាំរបស់ទីស្តីការគណៈរដ្ឋមន្ត្រី។

**គ.ជ.ប.ក.** អាចកៀរគរប្រភពធនធានពីមជ្ឈដ្ឋានក្នុងនិងក្រៅប្រទេសដើម្បីទ្រទ្រង់សកម្មភាពរបស់ខ្លួន។

**គ.ជ.ប.ក.** មានសិទ្ធិទទួលនិងចាត់ចែងប្រើប្រាស់ប្រភពធនធានស្របច្បាប់ផ្សេងៗ តាមការកំណត់របស់ច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន សម្រាប់ដំណើរការការងាររបស់ខ្លួន។

## ជំពូកទី៦
## អវសានប្បញ្ញត្តិ

**មាត្រា១១ .-**

អនុក្រឹត្យលេខ៧០ អនក្រ.បក ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ១៩៩៧ ស្តីពីការបង្កើតគណៈកម្មាធិការជាតិអូឡាំពិកសម្រាប់ជនពិការកម្ពុជា និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះត្រូវទុកជានិរាករណ៍។

**មាត្រា១២ .-**

សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ថ្ងៃសៅរ៍ ៩កើត ខែ ស្រាពណ៍ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ០២ ខែ សីហា ឆ្នាំ២០២៥

ពរស.២៥០១.០២២

**នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ

សូមឡាយព្រះហស្តលេខា

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**